ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ ០៥៤ រ.ដ.ក. អ.ជ.ប.គ.ញ.

ថ្ងៃ ចន្ទ ១៣ រោច ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែកុម្ភៈ និងលើកទិសដៅការងារខែមីនា ឆ្នាំ២០២៦

(ថ្ងៃទី១ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦)

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន(អ.ជ.ប.គ.ញ.) ក្នុងនាមជាសេនាធិការឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការសម្របសម្រួល ប្រមូលផ្តុំដឹកនាំ និងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមទិសដៅការងារដែលបានដាក់ចេញពីខែមករាកន្លងមក ដើម្បីសម្រេចបាននូវគោលនយោបាយប្រយុទ្ធប្រឆាំងគ្រឿងញៀនដែលបានដាក់ចេញកន្លងទៅ។ ជាក់ស្តែង ក្នុងខែកុម្ភៈ ឆ្នាំ២០២៦នេះ យើងបានអនុវត្ត និងទទួលបាននូវលទ្ធផល ដូចខាងក្រោម៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែកុម្ភៈ ឆ្នាំ២០២៦នេះ បទល្មើសគ្រឿងញៀន នៅតែបន្តមានស្ថានភាពប្រែប្រួលស្មុគស្មាញ ដោយក្រុមឧក្រិដ្ឋជនគ្រឿងញៀនតែងតែផ្លាស់ប្តូរវិធីសាស្ត្រ និងប្រើប្រាស់កលល្បិចថ្មីៗនៃការធ្វើសកម្មភាពចរាចរ ដឹកជញ្ជូន ជួញដូរនិងលួចលាក់កែច្នៃគ្រឿងញៀន ក្នុងនោះបទល្មើសគ្រឿងញៀនធំៗ ចាប់ពី ១គីឡូក្រាមឡើង ត្រូវបានសមត្ថកិច្ចបង្ក្រាប រួមមានបទល្មើសកែច្នៃនូវសារធាតុញៀន ១ករណី នៅខេត្តព្រះសីហនុ ចាប់យកគ្រឿងញៀន **១៣គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ២នាក់។ បទល្មើសដឹកជញ្ជូនជួញដូរគ្រឿងញៀនឆ្លងដែនតាមផ្លូវគោក(មកពីឡាវឆ្លងកាត់កម្ពុជាទៅវៀតណាម) ២ករណី នៅខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង ចាប់យកគ្រឿងញៀន **២៨គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ៥នាក់។ ដោយឡែកបទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរនូវគ្រឿងញៀនក្នុងផ្ទៃប្រទេស ៦ករណី នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តស្វាយរៀង ចាប់យកគ្រឿងញៀន **១០គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ២០នាក់។

**ការកត់សម្គាល់** ក្រៅពីស្ថានភាពនៃបទល្មើសគ្រឿងញៀនខាងលើ ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនឧសច្បាប់លើកទី១១ បានបង្ហាញឱ្យឃើញថា ការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន បានធ្វើសកម្មភាពជាប្រចាំ ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបានអនុវត្តកាន់តែសកម្ម និងមានប្រសិទ្ធភាពជាងមុន ការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់នៅតាមគោលដៅក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដោយធ្វើកិច្ចសន្យាជានាមិនឱ្យមានការជួញដូរនិងប្រើប្រាស់គ្រឿងញៀនក្នុងទីតាំង



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ. មានទីតាំងនៅក្នុងបរិវេណទីស្តីការក្រសួងមហាផ្ទៃ, Phone : (855) 23 721 648, (855) 16 721 648, P.O.Box: 151
E-mail: info@nacd.gov.kh Website: www.nacd.gov.kh

អាជីវកម្មរបស់ខ្លួនបានជាច្រើនកន្លែង និងការពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ តាមរយៈកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការផ្លាស់ប្តូរព័ត៌មាន និងចែករំលែកបទពិសោធទៅវិញទៅមកជាបន្តបន្ទាប់ផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមសហគមន៍ ទទួលបានលទ្ធផលដូចខាងក្រោម៖

#### ១.១. ការងារផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

បានសម្របសម្រួល និងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមប្រព័ន្ធផ្សព្វផ្សាយ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តាមរយៈគេហទំព័ររបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានការចូលអានចំនួន **៤៣.១២២ដង** (នៅខែមករា មានចំនួន ៤២.១២៦ដង) ច្រើនជាង ៩៩៦ដង កើនឡើង **២,៤%**

- ផ្សព្វផ្សាយអប់រំតាមរយៈឃ្លីបវីដេអូខ្លីៗ តាមបណ្តាញទំនាក់ទំនងសង្គម Facebook Page និងកម្មវិធីទូរស័ព្ទដៃ NoDrug របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- សហការសម្របសម្រួលជាមួយស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងបណ្តាញព័ត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន

- ជួបតំណាងក្រសួង ស្ថាប័ន ដៃគូ និងមហាជន ដើម្បីបង្កើនការចូលរួមផលិតមាតិកាសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទំនាក់ទំនងសង្គម

- បញ្ជ្រាបសារអប់រំស្តីពីបញ្ហាគ្រឿងញៀន ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនទៅក្នុងកម្មវិធីរបស់សមាគមសិល្បករខ្មែរ ក្រុមហ៊ុនហង្សមាសវីដេអូ ក្រុមហ៊ុនBKL បទចំរៀងនិងតន្ត្រីទេសចរណ៍របស់ក្រុមហ៊ុនហ្គូឡាក់ស៊ីណាវ៉ាត្រា កម្មវិធីប្រដាល់ដែលរៀបចំដោយសហព័ន្ធកីឡាប្រដាល់គុនខ្មែរនៅតាមបណ្តាទូរទស្សន៍នានា កម្មវិធីប្រកួតរៀបចំដោយសហព័ន្ធកីឡាអេឡិចត្រូនិក

- រៀបចំកិច្ចប្រជុំពិនិត្យ ពិភាក្សាបញ្ចប់សេចក្តីព្រាងលើឯកសារគោល ស្តីពីការយល់ដឹងអំពីគ្រឿងញៀន

- ឆ្លើយតបចម្ងល់មហាជននៅក្នុងFacebook និងPage របស់នាយកដ្ឋាន និងប្រធាននាយកដ្ឋានផ្សព្វផ្សាយ អប់រំ និងទំនាក់ទំនងសាធារណៈ ពាក់ព័ន្ធការព្យាបាលគ្រឿងញៀន និងចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ទទួលបានការគាំទ្រគួរកត់សម្គាល់

- ដឹកនាំក្រុមការងារចុះទៅមណ្ឌលឱកាសខ្ញុំ ដើម្បីជំរុញនិងផលិតមាតិកា ស្តីពីបញ្ហាគ្រឿងញៀន

- ដឹកនាំកិច្ចប្រជុំក្រុមបច្ចេកទេសក្រុមការងារបច្ចេកទេសផ្សព្វផ្សាយ អប់រំ ពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ដើម្បីពិនិត្យបញ្ចប់ឯកសារគោលស្តីពីគ្រឿងញៀន ។

#### ១.២. ការងារផ្សព្វផ្សាយអប់រំតាមសហគមន៍

បានសហការសម្របសម្រួល និងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ចូលរួមផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីចុះពង្រឹងការទប់ស្កាត់បទល្មើសគ្រឿងញៀននៅមណ្ឌលអប់រំកែប្រែទី៣ នៅខេត្តត្បូងឃ្មុំ

- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់ដល់សុខភាពបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន បារីអេឡិចត្រូនិក និងជំរុញការទាញនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នៅខេត្តកណ្តាល និងខេត្តកំពង់ចាម

- ចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ដល់សិស្សានុសិស្សនៃសាលាបញ្ញាសាស្ត្រអន្តរជាតិ នៅរាជធានីភ្នំពេញ

- អនុញ្ញាតឱ្យតំណាងសាកលវិទ្យាល័យការពារជាតិ ចូលរាយការណ៍អំពីលទ្ធផលនៃការរៀបចំឯកសារគោល ស្តីពីគ្រឿងញៀន នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

- ជួបក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទេសចរណ៍ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងកិច្ចការនារី ដើម្បីពិភាក្សាការងាររៀបចំផែនការសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនសម្រាប់ឆ្នាំ២០២៦ នៅទីស្តីការក្រសួងនីមួយៗ

- រៀបចំឯកសារ និងសហការជាមួយបណ្តាញគ្រីស្ទបរិស័ទនៃក្រុមប្រឹក្សាបណ្តាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា ដើម្បីអនុវត្តកម្មវិធីគ្រួសាររឹងមាំ( Strong Family ) នៅខេត្តព្រះសីហនុ

- សម្របសម្រួលជាមួយគណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ ដើម្បីជំរុញឱ្យរាជធានី ខេត្ត រៀបចំសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងកម្មវិធីទូរស័ព្ទដៃ NoDrug

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនបានចំនួន **១៦.៤៤១លើក** (នៅខែមករា មានចំនួន ១៦.៧៣៩លើក) តិចជាង ២៩៨លើក ថយចុះ **១,៨%** ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារ **៩៤៥.៣២៧នាក់** ស្រី ៥៣០.៤១៤នាក់ (នៅខែមករា មានចំនួន ១.០០១.៣០៨នាក់) តិចជាង ៥៥.៩៨១នាក់ ថយចុះ **៥,៦%**

- បំផុស ផ្សព្វផ្សាយ ជំរុញការទាញយកនិងប្រើប្រាស់នូវកម្មវិធីទូរស័ព្ទដៃ NoDrug រហូតមកដល់ពេលបច្ចុប្បន្ននេះមានចំនួន **៨៤.២៤១នាក់** (នៅខែមករា មានចំនួន ៧៩.៩៩៨នាក់) ច្រើនជាង ៤.២៤៣នាក់ កើនឡើង **៥,៣%**។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានយកចិត្តទុកដាក់ពង្រឹងគុណភាពសេវាព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ២.១.ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

សម្របសម្រួល និងអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- ក្រសួងសុខាភិបាល បានបន្តផ្តល់សេវាព្យាបាលឱសថជំនួសដោយមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន បានចំនួន ៥០នាក់ ស្រី ៨នាក់ ដែលមានទីតាំងនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត និងមន្ទីរបង្អែកច្បារអំពៅ៩

- អង្គការដៃគូបានអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន ដើម្បីបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗតាមឈាម បានចំនួន **៧៣០នាក់** ស្រី ១២៥នាក់ (នៅខែមករា មានចំនួន ៧០៨នាក់) ច្រើនជាង ២២នាក់ កើនឡើង **៣,១%**។

## ២.២.ការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

សម្របសម្រួល និងពង្រឹងសមត្ថភាពការងារព្យាបាល ស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- តាមរយៈការព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ក្រសួងសុខាភិបាលបានផ្តល់សេវាព្យាបាលដល់អ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន បានចំនួន ៣៤៨នាក់ ស្រី ១០៦នាក់ រួមមាន មន្ទីរពេទ្យបង្អែកចំនួន ៣១៦នាក់ ស្រី ៨៩នាក់ និងមណ្ឌលសុខភាពចំនួន ៣២នាក់ ស្រី ១៧នាក់
- ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន រួមមាន អ្នកចូលថ្មីចំនួន ១.៧០៧នាក់ ស្រី៩៨នាក់ អ្នកធ្វើសមាហរណកម្មចំនួន ១.៤៨១នាក់ ស្រី ៩៤នាក់ និងអ្នកកំពុងស្នាក់នៅចំនួន ៨.៧៨៥នាក់ ស្រី ៤៧៤នាក់
- រៀបចំកិច្ចប្រជុំពិភាក្សា និងផ្តល់ធាតុចូលពាក់ព័ន្ធនឹងការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន សម្រាប់ប្រធានបទពិភាក្សាក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.
- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារបន្តរបស់នាយកដ្ឋានគាំពារអ្នកញៀនគ្រឿងញៀន នៃអគ្គនាយកដ្ឋានស្តារសម្បទា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន ដល់មន្ត្រីបម្រើការងារនៅមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋចំនួន ៤ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.។

# ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ដើម្បីពង្រឹងប្រសិទ្ធភាពការងារអនុវត្តច្បាប់ ឈានទៅបំផ្លាញបណ្តាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន និងការទប់ស្កាត់ការចរាចរគ្រឿងញៀនគ្រប់ប្រភេទឆ្លងកាត់តំបន់ព្រំដែន បានបន្តសហការសម្របសម្រួលជាមួយស្ថាប័នអនុវត្តច្បាប់ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ តំបន់ អនុតំបន់ ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

## ៣.១.ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

ក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ បានសហការសម្របសម្រួលក្នុងការរៀបចំ ចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងកម្មវិធីនានា ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- រៀបចំវគ្គបណ្តុះបណ្តាលជំនាញក្នុងការទប់ស្កាត់ បង្ក្រាបការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុគីមីគ្រោះថ្នាក់ផ្សេងៗ តាមប្រព័ន្ធកុំព្យូទ័រ(CBT) ដល់មន្ត្រីនៃនាយកដ្ឋានអនុវត្តច្បាប់ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.៩

- រៀបចំប្រជុំពិភាក្សាការងាររបស់អនុគណៈកម្មការ បង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន តាមបញ្ញើប្រៃសណីយ៍ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.៣.

- រៀបចំពិធីប្រគល់-ទទួលឧបករណ៍ សម្ភារបច្ចេកទេស ដែលជាជំនួយរបស់សាធារណៈរដ្ឋកូរ៉េ របស់មជ្ឈមណ្ឌលព័ត៌មាន និងសម្របសម្រួលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មគ្រឿងញៀន(APICC) នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.៣.

- រៀបចំកិច្ចប្រជុំនៃក្រុមការងារប្រតិបត្តិការមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (SMCC) សម្រាប់បណ្តាប្រទេសជាសមាជិកទាំង៦ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ តាមប្រព័ន្ធអនឡាញ

- ទទួលការរាយការណ៍ពីបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug ចំនួន **២.៣៣៦ករណី** (នៅខែមករា មានចំនួន ៧០១ករណី) ច្រើនជាង ១.៦៣៥ករណី កើនឡើង **២៣៣,២៣%** ក្នុងនោះដោះស្រាយរួច ២.២០២ករណី កំពុងដោះស្រាយ ១៣៤ករណី

- បញ្ចូលទិន្នន័យព័ត៌មានពាក់ព័ន្ធករណីបង្ក្រាបបទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាម ឡើងទៅក្នុងប្រព័ន្ធទិន្នន័យរបស់គម្រោងសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Coordination Centre) បានចំនួន ១១ករណី ជនសង្ស័យ ចំនួន ២២នាក់ គ្រឿងញៀនចំនួន ៥២៨គីឡូក្រាម។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

តាមរយៈកិច្ចប្រតិបត្តិការរបស់កម្លាំងអនុវត្តច្បាប់ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

– បង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន **៩២៨ករណី**(នៅខែមករា មានចំនួន **៨៦៥**ករណី) ច្រើនជាង ៦៣ករណី កើនឡើង **៧,៣%**។ ឃាត់ខ្លួនជនសង្ស័យសរុបចំនួន **២.២២៥នាក់** ស្រី ១៣៧នាក់ (នៅខែមករា មានចំនួន **២.១០៨**នាក់) ច្រើនជាង ១១៧នាក់ កើនឡើង **៥,៦%** ក្នុងនោះ ជនជាតិខ្មែរ ២.០៩៤នាក់(ស្រី ១២៦នាក់) និងជនជាតិបរទេស ១៣១នាក់(ស្រី ១១នាក់) រួមមាន វៀតណាម ២៤នាក់ (ស្រី ៩នាក់) មីយ៉ាន់ម៉ា ១នាក់ ប៊ូតាន ៣នាក់ ឥណ្ឌូនេស៊ី ១០នាក់ ថៃ ៣នាក់ ម៉ាឡេស៊ី ២នាក់ និង ចិន ៨៨នាក់ (ស្រី ២នាក់) ក្នុងនោះចិនតៃវ៉ាន់ ១០នាក់

– **ចាប់យកគ្រឿងញៀន** ចំនួន **៦៩គ.ក្រ ២០២,០៤ក្រាម**(នៅខែមករា មានចំនួន ៥៤១គ.ក្រ ៩៥៤,២៦ក្រាម) តិចជាង ៤៧២គ.ក្រ ៧៥២,២២ក្រាម ថយចុះ **៨៧,២%**

– ចាប់យកសារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ ចំនួន **១០៥,៦០គីឡូក្រាម**

– ចាប់យកកញ្ឆាស្ងួត ចំនួន **៨៨៥ក្រាម**

– **សម្ភារចាប់យក**ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត រួមមាន រថយន្ត ៩គ្រឿង ម៉ូតូ ២៨៤គ្រឿង ទូរស័ព្ទ ១.១៤៦គ្រឿង ជញ្ជីង ៩៧គ្រឿង អាវុធខ្លី ៤ដើម អាវុធវែង ៣ដើម និងរូបិយវត្ថុជាតិ អន្តរជាតិ(៤.៨៥៨.៥០០រៀល ១.៤១១ដុល្លារ និង១.០៤០បាត)

– **អនុវត្តដីកា** បានចំនួន ៨០ដីកា ចាប់ខ្លួនជនសង្ស័យចំនួន ៥៧នាក់

– **ក្នុងចំនួនករណីគ្រឿងញៀនខាងលើ៖**

- ករណីបង្ក្រាបដោយ**សមត្ថកិច្ចនគរបាលចំនួន ៧៧៤ករណី** ឃាត់ខ្លួនជនសង្ស័យ ចំនួន ១.៨៦៦នាក់ (ស្រី ១០១នាក់)
- ករណីបង្ក្រាបដោយ**សមត្ថកិច្ចកងរាជអាវុធហត្ថចំនួន ១៥៤ករណី** ឃាត់ខ្លួនជនសង្ស័យ ចំនួន ៣៥៩នាក់ (ស្រី ៣៦នាក់)៥

– **ការកត់សម្គាល់លើបទល្មើសគ្រឿងញៀន៖**

- ករណីធំៗ ចាប់ពី **១គីឡូក្រាម**ឡើង មាន **៩ករណី** (ចោទពីបទសម្អាតប្រាក់**៤ ករណី**) ឃាត់ខ្លួនជនសង្ស័យបាន **២៧នាក់(ស្រី ៤នាក់)** ក្នុងនោះ ខ្មែរ ៣នាក់ វៀតណាម ១៥នាក់(ស្រី ៣នាក់) និងចិន ៩នាក់ (ស្រី ១នាក់) ចាប់យកគ្រឿងញៀន **៥២គីឡូក្រាម ៨០៨,៥៥ក្រាម** សារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ **៤គីឡូក្រាម ៥១៥,៨ក្រាម** និងកញ្ឆាក្រៀម **១០៦,៥ក្រាម**
- ករណីមធ្យម ចាប់ពី ១០០ក្រាមឡើង មាន ១៥១ករណី ឃាត់ខ្លួនជនសង្ស័យ ៣៨២នាក់
- ករណីតូចតាច ចាប់ពី ៩៩ក្រាមចុះក្រោម មាន ៧៦៨ករណី ឃាត់ខ្លួនជនសង្ស័យ ១.៨១៦នាក់។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល

ការចាត់តាំងអនុវត្តវិធានការរដ្ឋបាលបានចំនួន **១៩៦លើក** ក្នុងនោះ ចុះអប់រំម្ចាស់ទីតាំងអាជីវកម្មបាន ១២២លើក រួមមាន **៦គោលដៅ** (សណ្ឋាគារ ៤លើក ផ្ទះសំណាក់ ១០លើក ផ្ទះជួល ៧៤លើក បាបារាំង ៣លើក KTV ៣០លើក និងក្លឹប ១លើក) និងអញ្ជើញម្ចាស់ទីតាំងអាជីវកម្មមកប្រជុំបាន ៧៤លើក អ្នកចូលរួមចំនួន ៤.១២៩នាក់(ស្រី ១.៩៧២នាក់)។ ស្នងការដ្ឋាននគរបាលរាជធានីខេត្ត ចុះធ្វើតេស្តហ៊ើសរកសារធាតុញៀនលើក្រុមគោលដៅបានចំនួន **៦៨លើក** លើមុខសញ្ញាចំនួន **២២៧នាក់ (ស្រី ១២នាក់)** រកឃើញវិជ្ជមានសារធាតុញៀន **១៥៥នាក់** ត្រូវបានសមត្ថកិច្ចបញ្ជូនតាមនីតិវិធីច្បាប់ទៅទទួលយកសេវាបន្សាបនិងព្យាបាល។

### ៣.៤. ការងារមន្ទីរពិសោធន៍គ្រឿងញៀន

– បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ចំនួន **១.០៥៨សំណាក** ស្មើនឹង **៦០៣ករណី** ក្នុងនោះ សំណាកវិជ្ជមាន ១.០១៣សំណាក ស្មើនឹង ៩៥,៧៥% និងសំណាកអវិជ្ជមាន ៤៥សំណាក ស្មើនឹង ៤,២៥%

– បានផលិតតេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្វីតេស្ត (Marquis test) បានចំនួន ២.០០០តេស្ត និងប្រភេទកេតាមីន(Ketamine test) បានចំនួន ១.៩០០តេស្ត

– ចូលរួមកិច្ចប្រជុំ ស្តីពីគំនិតផ្តួចផ្តើមរួមរបស់ UNODC-UNIDO ដើម្បីពង្រឹងការអភិវឌ្ឍន៍ឧស្សាហកម្មឱសថ ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) តាមប្រព័ន្ធអនឡាញ

– សហការជាមួយតំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងតំណាងកំពង់ផែស្វយ័តភ្នំពេញ ដើម្បីប្រមូល វេចខ្ចប់ និងដឹកជញ្ជូនសារធាតុគីមីផ្សំគ្រោះថ្នាក់សម្រាប់ផលិតគ្រឿងញៀន ចំនួនប្រមាណ **១៥តោន** ចេញពីកំពង់ផែស្វយ័តភ្នំពេញ ទៅរក្សាទុកនៅឃ្លាំងសុវត្ថិភាព នៅខេត្តកំពង់ស្ពឺ

– បានផ្តល់តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង និងស្រោមសំបុត្ររក្សាវត្ថុតាង រួមមាន៖

- ប្រភេទម៉ាគ្វី ចំនួន ៨០០តេស្ត និងប្រភេទកេតាមីន ចំនួន ៦០០តេស្ត ជូនដល់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ស្រោមសំបុត្ររក្សាទុកវត្ថុតាង ចំនួន ១.១០០សន្លឹក ជូនដល់សាលាដំបូងខេត្តត្បូងឃ្មុំ និងសាលាដំបូងខេត្តបន្ទាយមានជ័យ។

ជាមួយគ្នានេះ តាមរយៈនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានផ្តល់តេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រ មានដូចជា៖ប្រភេទមេតំហ្វេតាមីន ចំនួន ២៨.៣២៥តេស្ត ជូនដល់អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានធនធានមនុស្ស កងទ័ពជើងគោក កងពលតូចថ្មើរជើងលេខ៣១ និងស្នងការដ្ឋានស្រាវជ្រាវនិងបង្ក្រាបបទល្មើស។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

បានអនុវត្តសកម្មភាពការងារគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ ដើម្បីបង្ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការលួចបង្វែរពីជំនួញស្របច្បាប់ យកទៅកែច្នៃគ្រឿងញៀនខុសច្បាប់ ទទួលបានលទ្ធផលដូចខាងក្រោម៖

– ជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងយន្តការគ្រប់គ្រងត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពត កែប ស្ទឹងត្រែង រតនៈគិរី និងមណ្ឌលគិរី

– ជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងការត្រួតពិនិត្យការដឹកជញ្ជូនសារធាតុញៀននិងសារធាតុគីមីផ្សំឆ្លងកាត់ព្រំដែន ជាមួយការិយាល័យគយនិងរដ្ឋាករប្រចាំច្រកទ្វារព្រំដែនព្រែកចាកនិងតន់ហាន់ខេត្តកំពត ត្រពាំងគ្រៀលខេត្តស្ទឹងត្រែង អូយ៉ាដាវខេត្តរតនៈគិរី និងច្រកទ្វារព្រំដែនដាក់ដាំនិងឡាប៉ាខេខេត្តមណ្ឌលគិរី។

– ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការចែករំលែកព័ត៌មានតាមរយៈប្រព័ន្ធទំនាក់ទំនងឧប្បត្តិហេតុសារធាតុគីមីផ្សំ(PICS) និងកំណត់អត្តសញ្ញាណសារធាតុគីមីផ្សំ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ(SINCB) តាមប្រព័ន្ធអនឡាញ

– ចូលរួមកិច្ចប្រជុំ ស្តីពីបច្ចុប្បន្នភាពតំបន់ និងការវាយតម្លៃ ការគំរាមកំហែងនៅតំបន់អាស៊ីអាគ្នេយ៍ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ(INCB) តាមប្រព័ន្ធអនឡាញ

– ក្រសួង ស្ថាប័នជំនាញមានសមត្ថកិច្ចពាក់ព័ន្ធ បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់ក្រុមហ៊ុនរោងចក្រ សហគ្រាស ក្នុងការនាំចូលនូវវត្ថុធាតុដើមផលិតឱសថ និងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន **៨.៨៤០តោន ៥០២គ.ក្រ** និង**១៦លីត្រ** (នៅខែមករា មានចំនួន ២.៩៤២តោន ៣៣០គ.ក្រ) ច្រើនជាង ៥.៨៩៨តោន ១៧២គ.ក្រ កើនឡើង **២០០%**។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

ដើម្បីពង្រឹង និងពង្រីកប្រសិទ្ធភាពក្នុងការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយបណ្តាប្រទេសជាប់ព្រំដែន ជាលទ្ធផលមានដូចខាងក្រោម៖

– បន្តពង្រឹងប្រសិទ្ធភាពការងារការិយាល័យទំនាក់ទំនងព្រំដែន(BLO) រវាងកម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម ជាប់ជាប្រចាំ

– បន្តពង្រឹងយន្តការភូមិ ឃុំ សង្កាត់ សគ្មានគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា

ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា និងសម្របសម្រួលកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ និងជាមួយការិយាល័យអង្គការ UNODC ជាលទ្ធផលមានដូចខាងក្រោម៖ ร

– បានសម្របសម្រួល និងធ្វើលិខិតឆ្លើយតបទៅក្រុមការងារ(IDEC) ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីការចូលរួមសន្និសីទអនុវត្តច្បាប់គ្រឿងញៀនអន្តរជាតិថ្នាក់តំបន់របស់ក្រុមការងារ(R-IDEC)

– បានសម្របស្រួលដល់មន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. ទៅប្រចាំការនៅការិយាល័យអគ្គព្រះរាជអាជ្ញានៃសាធារណៈរដ្ឋកូរ៉េ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

ដើម្បីបន្តពង្រឹងប្រសិទ្ធភាព និងធ្វើជាសេនាធិការក្នុងការចាត់តាំងដឹកនាំ អនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលក្ខណពហុវិស័យនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

– អនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ ចំពោះមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន និងមន្ត្រីជាប់កិច្ចសន្យា មកដល់បច្ចុប្បន្ននេះ**ចំនួន ១៣៩.៤១៣នាក់** ក្នុងនោះរកឃើញវិជ្ជមានសារធាតុញៀនចំនួន ១០៦នាក់ បណ្តេញចេញពីក្របខ័ណ្ឌចំនួន ១០៣នាក់ និងកំពុងតាមដាន ៣នាក់។ ដោយឡែកក្នុងខែកុម្ភៈ ឆ្នាំ២០២៦នេះ មានចំនួន ៧.៩២៦នាក់ បានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ រកឃើញវិជ្ជមានសារធាតុញៀនចំនួន ៣នាក់ (កំពុងតាមដាន)

– ជំរុញការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

– ជំរុញក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត បន្តអនុវត្តសេចក្តីណែនាំ ស្តីពីដំណើរការធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ

– ជំរុញការអនុវត្តផែនការសកម្មភាព ស្តីពីការចាត់តាំងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១

– ប្រជុំពិនិត្យ និងពិភាក្សាការងារពាក់ព័ន្ធនឹងការត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ប្រជុំត្រួតពិនិត្យលើការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំខែមករា និងលើកទិសដៅការងារខែកុម្ភៈឆ្នាំ២០២៦ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ប្រជុំពិនិត្យ ពិភាក្សានិងផ្តល់ធាតុចូលទៅលើការងារត្រៀមរៀបចំកែសម្រួលប្រកាស ស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឱ្យលក់ដោយខុសច្បាប់ នៅអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ.

– ចូលរួមកិច្ចប្រជុំលើកទី២២ របស់គណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

– ចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំដោយក្រសួងអធិការកិច្ច នៅខេត្តសៀមរាប

– កិច្ចប្រជុំពិនិត្យ ពិភាក្សា និងផ្តល់ធាតុចូលលើសមិទ្ធផលនិងវឌ្ឍនភាពលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនពាក់កណ្តាលអាណត្តិ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– រៀបចំរបាយការណ៍ និងផ្តល់ធាតុចូលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ឆ្នាំ២០២៥ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍សកម្មភាពការងាររបស់រាជរដ្ឋាភិបាល

– រៀបចំបញ្ជូនសេចក្តីព្រាងមេពាក្យ សទ្ទានុក្រមបច្ចេកសព្ទពាក់ព័ន្ធការងារគ្រឿងញៀន ជូនគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៃក្រសួងមហាផ្ទៃ

– បន្តរៀបចំការអង្កេតអំពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន

– បន្តសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ជំរុញឱ្យមានប្រសិទ្ធភាពការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន និងការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតាមបណ្តាភូមិសាស្ត្រស្មុគស្មាញ។

**ក្រៅពីលទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខាងលើ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រី**ចូលរួមដូចខាងក្រោម៖

– ក្នុងពិធីបិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងបូកសរុបចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅទីស្តីការក្រសួងមហាផ្ទៃ

– ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សា ១ខ្នង និងពិធីប្រគេន-ប្រគល់សញ្ញាបត្រជូនសមាណនិស្សិត-និស្សិត ជ័យលាភនៃពុទ្ធិកសាកលវិទ្យាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្រោមអធិបតីភាព**ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅខេត្តកំពង់ចាម

– កម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ

– កិច្ចប្រជុំប្រចាំខែកុម្ភៈ ស្តីពីការសម្របសម្រួលការងារអន្តរអង្គភាពចំណុះក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– ពិធីប្រកាសសមាសភាពគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងទេសចរណ៍ ក្រសួងផែនការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

– កិច្ចប្រជុំ ស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ និងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែកុម្ភៈ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

– កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងរបាយការណ៍ ស្ដីពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៥ នៅទីស្ដីការគណៈរដ្ឋមន្ត្រី

– កិច្ចប្រជុំពិនិត្យ និងផ្ដល់ធាតុចូលលើកម្រងសំណួរនៃរបាយការណ៍ ស្ដីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០២៥ របស់ក្រសួងការងារសហរដ្ឋអាម៉េរិក នៅទីស្ដីការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

– កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល និងសេចក្ដីព្រាងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៥ និងទម្រង់នៃការផ្ដល់ធាតុចូលសម្រាប់រៀបចំរបាយការណ៍ពាក់កណ្ដាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា នៅទីស្ដីការក្រសួងផែនការ

– កិច្ចប្រជុំពិនិត្យ និងពិភាក្សា ស្ដីពីការរៀបចំនិយាមនីតិវិធីប្រតិបត្តិស្តង់ដារ(SOP) សម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ

– សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ ស្ដីពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មលើកទី២ ដែលរៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅរាជធានីភ្នំពេញ

– កិច្ចប្រជុំពិនិត្យពិភាក្សាលើវឌ្ឍនភាពការងារ នៃការរៀបចំសៀវភៅសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខសង្គមនៃក្រសួងមហាផ្ទៃ នៅបណ្ឌិត្យសភានគរបាលកម្ពុជា។

## III. ទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែមីនា ឆ្នាំ២០២៦

ដើម្បីបន្តអនុវត្តឱ្យមានប្រសិទ្ធភាពលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានដាក់ចេញនូវទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២៦ ដូចខាងក្រោម៖

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** បន្តសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ពង្រឹងការងារផ្សព្វផ្សាយអប់រំ តាមរយៈវិទ្យុ ទូរទស្សន៍ ទូរស័ព្ទដៃ សិល្បៈភាពយន្ត លើស្លាកសញ្ញាផលិតផលក្នុងស្រុក និងតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងទៀត។

**១.២.** បន្តសម្របសម្រួលនិងជំរុញក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ផលិតមាតិកាពាក់ព័ន្ធការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.៣.** បន្តសហការនិងជំរុញរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការទាញយក និងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug។

**១.៤.** បន្តពង្រឹងការបញ្ជ្រាបខ្លឹមសារអប់រំអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនតាមរយៈសកម្មភាពផ្សេងៗរបស់ដៃគូ។

**១.៥.** បន្តសហការនិងសម្របសម្រួលដើម្បីត្រៀមរៀបចំចុះអនុស្សរណៈនៃការយោគយល់រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហព័ន្ធកីឡាបាល់ទាត់ និងសហភាពសហព័ន្ធយុវជនកម្ពុជា។

**១.៦.** បន្តចលនា កៀរគរឱ្យមានការចូលរួមផុលផុសនិងគាំទ្រពីគ្រប់មជ្ឈដ្ឋានសង្គមលើការងារផ្សព្វផ្សាយអប់រំ ស្ដីពីបញ្ហាគ្រឿងញៀន។

**១.៧.** បន្តសហការជាមួយបណ្ដាញគ្រីស្ទបរិស័ទនៃក្រុមប្រឹក្សាបណ្ដាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា ដើម្បីអនុវត្តកម្មវិធីគ្រួសាររឹងមាំ( Strong Family ) នៅខេត្តព្រះសីហនុ។

**១.៨.** ត្រៀមចូលរួមសិក្ខាសាលាផ្សព្វផ្សាយ អប់រំ ស្ដីពីផលប៉ះពាល់ដល់សុខភាពបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន និងបារីអេឡិចត្រូនិក នៅតាមគ្រឹះស្ថានសិក្សាក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ន

**១.៩.** ត្រៀមចូលរួមសិក្ខាសាលាស្តីពីការលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងវិស័យគ្រីស្ទសាសនា នៅព្រះវិហារភ្លឺអំណរនៃព្រះគ្រីស្ទខេត្តកំពង់ស្ពឺ។

**១.១០.** ត្រៀមចូលរួមជាវាគ្មិនក្នុងកម្មវិធីបង្កើនចំណេះដឹងទូទៅក្រោមប្រធានបទ ការយល់ដឹងអំពីគ្រឿងញៀន និងផលប៉ះពាល់នៃបារីអេឡិចត្រូនិក នៅសាលាប៊ែលធីអន្តរជាតិ ។

**១.១១.** ត្រៀមសហការរៀបចំកម្មវិធីចុះហត្ថលេខាទទួលស្គាល់លើឯកសារគោលស្តីពីគ្រឿងញៀន នៅសាកលវិទ្យាល័យការពារជាតិ។

**១.១២.** ត្រៀមចូលរួមផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីចុះពង្រឹងការទប់ស្កាត់បទល្មើសគ្រឿងញៀននៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត។

**១.១៣.** ត្រៀមរៀបចំឯកសារ ខ្លឹមសារ ដើម្បីត្រៀមចូលរួមផ្សព្វផ្សាយពីចំណេះដឹងពីបញ្ហាគ្រឿងញៀន និងជំរុញដែលប្រើប្រាស់ App NoDrug ក្នុងពិធីបុណ្យទន្លេលើកទី ១០ នៅខេត្តក្រចេះ។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

**២.១.** បន្តសម្របសម្រួលជាមួយក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការផ្តល់ទិន្នន័យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន។

**២.២.** បន្តជំរុញមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន ឱ្យរៀបចំមាតិកាសម្រាប់ដាក់លើកម្មវិធីទូរស័ព្ទដៃ NoDrug។

**២.៣.** បន្តជំរុញការអនុវត្ត(MOU) ជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអនុវត្ត ស្តីពីការបង្ការ ការប្រើប្រាស់គ្រឿងញៀន ភីអេសឌី ប្រទេសវៀតណាម។

**២.៤.** បន្តរៀបចំបណ្តុះបណ្តាលការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន ដល់មន្ត្រីបម្រើការងារនៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន។

**២.៥.** ត្រៀមសហការសម្របសម្រួលជាមួយគណៈអភិបាលខេត្តស្វាយរៀង ដើម្បីចុះពិនិត្យទីតាំងសាងសង់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តស្វាយរៀង។

**២.៦.** ត្រៀមសម្របសម្រួលជាមួយតំណាងក្រសួងសន្តិសុខសាធារណៈនៃសាធារណៈសង្គមនិយមវៀតណាម ពាក់ព័ន្ធនឹងការស្នើសុំជំនួយសម្រាប់សាងសង់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តស្វាយរៀង។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ក្នុងការទប់ស្កាត់ជាអាទិភាពនូវការចរាចរគ្រឿងញៀនឆ្លងកាត់ព្រំដែន តាមផ្លូវគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍ ពិសេសនៅតាមតំបន់ព្រំដែន។

**៣.២.** ត្រៀមផ្សព្វផ្សាយខ្លឹមសារសេចក្តីសម្រេច ស្តីពីការរៀបចំនឹងប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៣.៣.** ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលជំនាញក្នុងការទប់ស្កាត់ បង្ក្រាបការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុគីមីគ្រោះថ្នាក់ផ្សេងៗ តាមប្រព័ន្ធកុំព្យូទ័រ(CBT) ដល់មន្ត្រីនៃនាយកដ្ឋានអនុវត្តច្បាប់។

**៣.៤. ការងារមន្ទីរពិសោធន៍គ្រឿងញៀន៖**

– បន្តពិនិត្យ និងធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ដើម្បីដោះស្រាយការកកស្ទះសំណុំរឿងរបស់សាលាដំបូងរាជធានី ខេត្ត

– បន្តផលិតឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្វីតេស្ត ( Marquis test) និងកេតាមីនតេស្ត ( Ketamine test ) ដើម្បីមានលទ្ធភាពផ្គត់ផ្គង់ឧបករណ៍ទាំងនេះ ដល់ស្ថាប័នអនុវត្តច្បាប់ សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់

– ត្រៀមចូលរួមធ្វើតេស្តរកសារធាតុក្នុងទឹកមូត្រជូនដល់មន្ត្រីរាជការតាមក្រសួង ស្ថាប័ន អង្គភាពមួយចំនួន ។

**៣.៥.** ត្រៀមចុះសហការ ពិនិត្យ និងពិភាក្សាក្នុងការត្រៀមរៀបចំបង្កើតការិយាល័យ BLO កោះរការ។

**៣.៦.** ត្រៀមមរៀបចំកិច្ចប្រជុំបិទប្រតិបត្តិការមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (SMCC) ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

**៤.១.** ត្រៀមសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

**៤.២.** បន្តចុះជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងយន្តការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាពគយនិងរដ្ឋាករតាមច្រកទ្វារព្រំដែន។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

**៥.១.** បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ត្រីភាគី ពហុភាគី ជាមួយប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំដែលបានឯកភាព ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥.២.** បន្តសម្របសម្រួល និងសហការជាមួយប្រទេសជាប់ព្រំដែន ដើម្បីពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៥.៣.** ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទ្វេភាគី ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ លើកទី១៩ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៦.២.** បន្តចូលរួមសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូ នៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាពិសេសបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ។

**៦.៣.** បន្តសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសស៊ើបអង្កេតជាន់ខ្ពស់ ការគ្រប់គ្រងកន្លែងកើតហេតុ ការឃ្លាំងមើល និងការប្រគល់ទទួលដោយមានការឃ្លាំមើល នៅខេត្តសៀមរាប។

**៦.៤.** ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្ដីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមលម្ហសមុទ្រ រវាងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយកងកម្លាំងឆ្មាំសមុទ្រនៃសាធារណៈរដ្ឋកូរ៉េ។

**៦.៥.** ត្រៀមរៀបចំនិងចូលរួមសម្រាប់ព្រឹត្តិការណ៍អមក្នុងសម័យប្រជុំលើកទី៦៩ នៃគណៈកម្មការគ្រឿងញៀន(CND) ដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនធ្វើជាម្ចាស់ព្រឹត្តិការណ៍ នៅប្រទេសអូទ្រីស។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**៧.១.** បន្តពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្ដីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧.២.** បន្តពង្រឹងការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាល ស្ដីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

**៧.៣.** បន្តអនុវត្តផែនការ ស្ដីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

**៧.៤.** ត្រៀមអនុវត្តដំណើរការអង្កេតអំពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន។

**៧.៥.** ត្រៀមសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដើម្បីរៀបចំ និងកែសម្រួលសេចក្ដីប្រកាសស្ដីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឱ្យលក់ដោយខុសច្បាប់។

**៧.៦.** ត្រៀមរៀបចំបញ្ចូលសារធាតុញៀនប៉ះពាល់ប្រព័ន្ធប្រសាទ និងសារធាតុគីមីផ្សំថ្មីៗ ចូលទៅក្នុងឧបសម្ព័ន្ធនៃច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**៧.៧.** ត្រៀមចូលរួមត្រួតពិនិត្យ និងវង្វាយតម្លៃរបាយការណ៍ពាក់កណ្ដាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ របស់រាជរដ្ឋាភិបាល នីតិកាលអី៧ នៃរដ្ឋសភា។

**៧.៨.** ត្រៀមចូលរួមប្រជុំអន្តរក្រសួងកម្រិតថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល។

**៧.៩.** ត្រៀមសហការជាមួយក្រសួងអធិការកិច្ច ដើម្បីផ្សព្វផ្សាយច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តកំពង់ឆ្នាំង។

**៧.១០.** ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

**អគ្គលេខាធិការ**

**នាយឧត្តមសេនីយ៍ មាស-វីរិទ្ធ**

**ចម្លងជូន៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.
  " ដើម្បីគោរពជូនជ្រាប "
- ឯកឧត្តមអនុប្រធាន និងសមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- អគ្គលេខាធិការរងនៃអ.ជ.ប.គ.ញ.
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
- នាយកដ្ឋាននិងមន្ទីរពិសោធន៍នៃ អ.ជ.ប.គ.ញ.
  " ដើម្បីមុខការ "
- ឯកសារ កាលប្បវត្តិ